**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

**លេខាធិការដ្ឋាន**

លេខៈ ០៨៦ គ.ស.ណ /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ:** ការពង្រឹងការអនុវត្តតួនាទី និងភារៈកិច្ចរបស់ទីប្រឹក្សាថ្នាក់រាជធានី ខេត្តដែលបំពេញការងារក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំ និងផ្តល់កិច្ចសន្យាបម្រើការងារជូនដល់ទីប្រឹក្សាថ្នាក់រាជធានី ខេត្តទាំងអស់ដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ ហើយទីប្រឹក្សាថ្នាក់រាជធានី ខេត្តទាំងនោះត្រូវអនុវត្តតាមតួនាទី និងភារៈកិច្ចដូចដែលបានចែងក្នុងលក្ខខណ្ឌការងារ (TOR) ដែលបានកំណត់។ ផ្អែកតាមការសម្ភាសន៍វាយតម្លៃសមត្ថភាពកាលពីខែធ្នូ ឆ្នាំ២០១៦ លេខាធិការដ្ឋាន គ.ជ.អ.ប បានសង្កេតឃើញថា ទីប្រឹក្សាថ្នាក់រាជធានី ខេត្តមួយចំនួនដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ មិនបានអនុវត្តពេញលេញតាមភារៈកិច្ចដូចដែលបានចែងក្នុងលក្ខខណ្ឌការងារ (TOR) នោះឡើយ។ អាស្រ័យហេតុនេះ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋបាលរាជធានី ខេត្ត លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំដូចខាងក្រោម៖

១. រដ្ឋបាលរាជធានី ខេត្តត្រូវចាត់ចែងផ្សព្វផ្សាយនូវលក្ខខណ្ឌការងារ (TOR) របស់ទីប្រឹក្សាថ្នាក់រាជធានី ខេត្តទាំងអស់ដែលកំពុងបំពេញការងារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីឱ្យទីចាត់ការពាក់ព័ន្ធដឹងពីកិច្ចការនានាដែលទីប្រឹក្សាទាំងនោះត្រូវជួយគាំទ្រ និងផ្តល់នូវកិច្ចសហការណ៍ជាមួយទីប្រឹក្សាទាំងនោះ។ ទន្ទឹមគ្នានេះ រដ្ឋបាលរាជធានី ខេត្តត្រូវចាត់ចែងជម្រុញដល់ដំណើរការមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សឱ្យមានប្រសិទ្ធភាពខ្ពស់។

២. ក្នុងឆ្នាំ២០១៧នេះ មានទីប្រឹក្សាថ្នាក់រាជធានី ខេត្តមួយចំនួនត្រូវបានផ្តល់កិច្ចសន្យារយៈពេល ០៣ខែ និង០១ឆ្នាំ។ មុនពេលបញ្ចប់កិច្ចសន្យា ទីប្រឹក្សាថ្នាក់រាជធានី ខេត្តទាំងនោះនឹងត្រូវឆ្លងកាត់ការវាយតម្លៃសមត្ថភាពឡើងវិញដោយលេខាធិការដ្ឋាន គ.ជ.អ.ប ដែលការវាយតម្លៃនេះនឹងឆ្លុះបញ្ចាំងសមត្ថភាពពិតប្រាកដក្នុងការអនុវត្តលក្ខខណ្ឌការងារ (TOR) ខាងលើនេះ។

ទន្ទឹមនឹងវិធានការខាងលើនេះ ដើម្បីធានាដល់ប្រសិទ្ធភាពនៃការផ្តល់ជំនួយបច្ចេកទេសដល់រដ្ឋបាលរាជធានី ខេត្ត លេខាធិការដ្ឋាន គ.ជ.អ.ប មានគោលបំណងរៀបចំផ្លាស់ប្តូរទីកន្លែងបំពេញការងារ (ប្តូររាជធានី ខេត្ត) ចំពោះទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត (PPMA) ដែលធ្លាប់បានបំពេញការងារនៅរដ្ឋបាលរាជធានី ខេត្តណាមួយលើសពីរយៈពេល០៥ឆ្នាំឡើងទៅ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាបជាព័ត៌មាន និងចាត់ចែងអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**